អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១០

# ការិយាល័យសហចៅក្រមស៊ើបអង្កេត

## រយៈពេលកំណត់ក្នុងការដាក់ព័ត៌មានបន្ថែមចំពោះអ្នកដាក់ពាក្យស្នើសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២

សហចៅក្រមស៊ើបអង្កេតសូមប្រកាសថា ចំពោះអ្នកដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ ដែលបានដាក់ពាក្យសុំនៅអង្គភាពគាំទ្រជនរងគ្រោះក្នុងកាលបរិច្ឆេទដែលកំណត់ត្រឹមថ្ងៃ ២៩ ខែ មករា ឆ្នាំ ២០០៩ ពួកគេអាចស្នើសុំដាក់ព័ត៌មានបន្ថែមទៀតបាន ប្រសិនបើពួកគេយល់ថាចាំបាច់។

លទ្ធភាពនេះត្រូវបានផ្តល់ជូនចំពោះអ្នកដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនច្បាស់លាស់ក្នុងចិត្តថា ព័ត៌មានដែលខ្លួនបានផ្តល់កាលពីពេលមុនឋិតនៅក្នុងវិសាលភាពនៃការស៊ើបសួរ ដូចដែលពិពណ៌នានៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់ សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩[1] ប៉ុន្តែខ្លួនយល់ថាខ្លួនមានព័ត៌មានបន្ថែម ដែលអាចពាក់ព័ន្ធជាមួយនឹងពាក្យសុំរបស់ខ្លួនទាក់ទងនឹងបញ្ហាណាមួយ។

ដើម្បីបញ្ជូនព័ត៌មានទាំងនោះមកឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការពិនិត្យ និងវិភាគ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលបានដាក់ពាក្យសុំរួចមកហើយ អាចធ្វើការដាក់ព័ត៌មានបន្ថែមដែលខ្លួនមានមកអង្គភាពគាំទ្រជនរងគ្រោះ ឲ្យបានមុនថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១០។

អង្គភាពគាំទ្រជនរងគ្រោះរបស់ អ.វ.ត.ក. អាចជួយសម្រួល និងផ្តល់ការណែនាំបន្ថែមទាក់ទងនឹងបញ្ហានេះ។

[1] http://www.eccc.gov.kh/khmer/cabinet/press/105/ECCC_Press_Release_5_Nov_2009_Kh.pdf

**អង្គភាពគាំទ្រជនរងគ្រោះ**

**ផ្ទះលេខ ៦A ផ្លូវលេខ ២១ សង្កាត់ទន្លេបាសាក់**

**ខណ្ឌ ចំការមន រាជធានីភ្នំពេញ**

**ប្រទេសកម្ពុជា**

**ទូរស័ព្ទទំនាក់ទំនង៖ 012 842 861, 097 742 4218 ឬ 023 214 291**

ម៉ោងធ្វើការចាប់ពីម៉ោង ៨ ព្រឹក ដល់ម៉ោង ៥ រសៀល ពីថ្ងៃ ច័ន្ទ ដល់ថ្ងៃ សុក្រ លើកលែងថ្ងៃឈប់សម្រាកផ្លូវការ។